ទីភ្នាក់ងារសុខភាពផ្លូវចិត្តនៃសហគមន៍	ពលរដ្ឋដែលបានបំរើ	ទីកន្លែងជានានា នៃការិយាល័យ
ASIAN COUNSELING AND REFERRAL SERVICE (អង្គការផ្តល់និវាទ និងសេវាបញ្ជូនអាស៊ី) 206-695-7600 www.acrs.org	▪ ជនជាតិដើកោះអាស៊ី/សមុទ្រចាំ|ស៊ីហ្វិក ▪ គ្រប់ក្រុមអាយុទាំងអស់	▪ តំបន់កណ្តាល *(បំរើបុគ្គលម្នាក់ៗមកពីទូទាំង យើងខោនធី)*
CATHOLIC COMMUNITY SERVICES 206-328-5097 www.ccsww.org	▪ កុមារនិងគ្រួសារ	▪ Seattle ▪ Kent
COMMUNITY HOUSE MENTAL HEALTH (មន្ទីរសុខភាពផ្លូវចិត្តសហគមន៍) 206-322-2387	▪ មនុស្សធំ	▪ Capitol Hill
COMMUNITY PSYCHIATRIC CLINIC (មន្ទីរគ្លីនិកវិកលចរិតសហគមន៍) 206-545-2354 206-461-3614 www.cpcwa.org	▪ គ្រប់ក្រុមអាយុទាំងអស់	▪ Belltown ▪ Lake City Way ▪ Northgate ▪ Pioneer Square ▪ Wallingford
CONSEJO COUNSELING AND REFERRAL SERVICES (អង្គការផ្តល់និវាទ និងសេវាបញ្ជូន CONSEJO) 206-461-4880 www.consejo-wa.org	▪ សំខាន់សំរាប់ជនជាតិអេស្ប៉ាញ/ឡាតាំង ▪ គ្រប់ក្រុមអាយុទាំងអស់	▪ តំបន់កណ្តាល ▪ Rainier
DOWNTOWN EMERGENCY SERVICE CENTER (មជ្ឈមណ្ឌលសង្គ្រោះអាសន្នដោនថោន) 206-464-1570 www.desc.org	▪ មនុស្សធំ	▪ Belltown ▪ Pioneer Square
EVERGREEN HEALTHCARE (សេវាថែទាំសុខភាព EVERGREEN) 206-923-6300 www.evergreenhealthcare.org	▪ មនុស្សធំចំណាស់ ▪ មនុស្សធំស្មុកស្មាញផ្នែកពេទ្យ និង មនុស្សធំចំណាស់	▪ ខោនធីទាំងមូល (មិនសំដៅ មូលដ្ឋានការិយាល័យ)
HARBORVIEW MENTAL HEALTH SERVICES (សេវាថែទាំសុខភាពផ្លូវចិត្ត HARBORVIEW) 206-744-9600 www.uwmedicine.washington.edu	▪ មនុស្សធំ ▪ មនុស្សធំចំណាស់	▪ First Hill
NAVOS 206-248-8226 www.navos.org	▪ គ្រប់ក្រុមអាយុទាំងអស់	▪ Burien ▪ Seattle ខាងលិច
SEA MAR COMMUNITY HEALTH CENTERS (មជ្ឈមណ្ឌលសុខភាពសហគមន៍ SEA MAR) 206-766-6976 *(South Park)* 425-460-7114 *(Bellevue)* www.seamar.org	▪ សំខាន់សំរាប់ជនជាតិអេស្ប៉ាញ/ឡាតាំង ▪ គ្រប់ក្រុមអាយុទាំងអស់	▪ South Park ▪ Bellevue
SEATTLE CHILDREN'S (អង្គការកុមារក្រុងស៊ីអាតថុល) 206-987-3560 www.seattlechildrens.org	▪ កុមារនិងគ្រួសារ	▪ បរិវេណចាត់ការមន្ទីរពេទ្យ ▪ Bellevue ▪ តំបន់កណ្តាល
SEATTLE CHILDREN'S HOME (មន្ទីរកុមារក្រុងស៊ីអាតថុល) 206-283-3300 www.seattlechildrenshome.org	▪ កុមារនិងគ្រួសារភាគច្រើន	▪ Queen Anne
SEATTLE COUNSELING SERVICE (សេវាផ្តល់និវាទក្រុងស៊ីអាតថុល) 206-323-1768 www.seattlecounseling.org	▪ ផ្ទៃភេទយុវវ័យភាគច្រើន ▪ គ្រប់ក្រុមអាយុទាំងអស់	▪ Capitol Hill
SOUND MENTAL HEALTH (មន្ទីរសុខភាពផ្លូវចិត្ត SOUND) 206-302-2300 206-302-2209 *(TTY)* www.smh.org	▪ គ្រប់ក្រុមអាយុទាំងអស់ ▪ ថ្នង់និងស្តាប់មិនស្វាវ្ច ▪ ពិការផ្នែកចំណីនលួតលាស់	▪ Auburn/Kent ▪ Bellevue ▪ Seattle ខាងជើង ▪ Seattle Madison ▪ Seattle ▪ Redmond ▪ Tukwila
THERAPEUTIC HEALTH SERVICES (សេវាព្យាបាលសុខភាព) 206-322-7676 *(Youth/Families)* 206-726-1980 *(មនុស្សធំ)* www.therapeutichealth.org	▪ អាហ្វ្រិកអាមេរិកភាគច្រើន ▪ គ្រប់ក្រុមអាយុទាំងអស់	▪ តំបន់កណ្តាល (សាខាសេវាតំបន់ យុវជន និងគ្រួសារកណ្តាល) ▪ Rainier Valley *(មនុស្សធំ)*
VALLEY CITIES COUNSELING AND CONSULTATION (អង្គការផ្តល់និវាទនិងពិគ្រោះយោបល់ក្រុង VALLEY) 253-939-4055 www.valleycities.org	▪ គ្រប់ក្រុមអាយុទាំងអស់	▪ Auburn ▪ Federal Way ▪ Kent ▪ Renton ▪ យើងខោនធីខាងត្បូង
YOUNG MEN'S CHRISTIAN ASSOCIATION OF GREATER SEATTLE (សមាគមគ្រីស្ទានទៅមហាក្រុងស៊ីអាតថុលនៃបុរសវ័យក្មេង) 206-382-5340 www.seattleymca.org	▪ កុមារនិងគ្រួសារភាគច្រើន	▪ តំបន់កណ្តាល

សេវាផ្តោតលើការស្តារសុខភាពផ្លូវចិត្ត

RSN (បណ្តាញឧបត្ថម្ភតំបន់) នៃយើងខោនធីគឺប្តេជ្ញាធានាឲ្យមានសេវាកម្មផ្សព្វផ្សាយ និងឧបត្ថម្ភដល់ដំណើរស្តារសុខភាពផ្លូវចិត្ត។

ដំណើរស្តារសុខភាពផ្លូវចិត្តគឺជាដំណើរការទៅរកការធ្វើឲ្យជាសះស្បើយ ហើយនិងការផ្លាស់ប្តូរឡើងវិញ ដែលអាចធ្វើឲ្យបុគ្គលម្នាក់ដែលមានបញ្ហាសុខភាពផ្លូវចិត្ត បានរស់នៅក្នុងជីវិតមួយដោយមានន័យនៅក្នុងសហគមន៍ទៅតាមជំរើសរបស់គេ នៅពេលខំប្រឹងប្រែងដើម្បីសំរេចពេញលេញនូវលទ្ធភាពរបស់គេ។
- សេចក្តីថ្លែងជាឯកច្ឆន្ទនៃជាតិលើផ្នែកដំណើរស្តារសុខភាពផ្លូវចិត្ត

គោលការណ៍ស្តារសុខភាពផ្លូវចិត្តសំរាប់សេវានានារួមមាន :

- សេវានានាដែលបានអភិវឌ្ឍនៅក្នុងភាពជាដៃគូជាមួយមនុស្សម្នាក់ ដើម្បីឲ្យជួបតាមសេចក្តីត្រូវការរបស់គេ។
- ការធ្វើផែនការដែលបង្កើតភាពរឹងមាំ និងលើកឡើងពីគោលដៅរបស់មនុស្សម្នាក់។
- ការបន្ថយរោគសញ្ញានិង/ឬបង្រៀនពីមធ្យោបាយដើម្បីដោះស្រាយជាមួយនឹងរោគសញ្ញា។
- ការជួយដើម្បីកសាងជីវិតរបស់មនុស្សម្នាក់ដែលចង់រស់នៅក្នុងសហគមន៍, ដោយរួមទាំងការងារ, ការអប់រំ, ការកំសាន្ត, សុខភាព, ចេតភាព, គ្រួសារ, និងមិត្តសំឡាញ់។
- សេចក្តីសង្ឃឹម, ការគោរព, និងការទទួលខុសត្រូវទៅវិញទៅមក។

ធនធានានា

រ៉ូបម៉ូសគ៊ីនៃដំណើរស្តារសុខភាពផ្លូវចិត្តនៅយើងខោនធី
- http://www.kingcounty.gov/healthServices/MentalHealth/Recovery.aspx

សម្ព័ន្ធភាពជាតិផ្នែកជម្ងឺផ្លូវចិត្ត (NAMI)
- NAMI Greater Seattle (អង្គការ NAMI មហាក្រុងស៊ីអាតថុល)
  - http://www.nami-greaterseattle.org/
- NAMI South King County (អង្គការ NAMI យើងខោនធីខាងត្បូង)
  - http://www.nami.org/sites/NAMISouthKingCounty
- NAMI Eastside (អង្គការ NAMI ខាងកើត)
  - http://www.nami-eastside.org/

KCRSN Brochure, Rev 6/09 – Cambodian

King County

បណ្តាញតំបន់ឧបត្ថម្ភ (RSN) យើងខោនធី

នាយកដ្ឋានយើងខោនធី
ក្រសួងសេវាសហគមន៍និងមនុស្សជាតិ

សេវា សុខភាពផ្លូវចិត្ត សាធារណៈ ក្នុងយើងខោនធី

បណ្តាញទូរស័ព្ទវិបត្តិ 24- ម៉ោង
206-461-3222
លេខមិនគិតថ្លៃ 1-866-4-CRISIS (427-4747)
ទូរស័ព្ទ TTY 206-461-3219

សេវាអតិថិជន (ច័ន្ទ–សុក្រ, ម៉ោង 8 ព្រឹក– 5 ល្ងាច)
206-263-8997
លេខមិនគិតថ្លៃ 1-800-790-8049
ទូរស័ព្ទ TTY 206-205-0569

ការទទួលបណ្តឹងការភ្ជាប់ផ្នែកសុខភាពផ្លូវចិត្ត
206-205-5329
លេខមិនគិតថ្លៃ 1-800-790-8049, #3

ការិយាល័យរដ្ឋបាល
401 Fifth Avenue, Suite 400
Seattle, WA 98104
206-263-9000
ទូរស័ព្ទ TTY 206-205-0569
រ៉ូបម៉ូសគ៊ី : www.kingcounty.gov/dchs/mhd/

តើនរណាមានលក្ខណសម្បត្តិ ទទួលសេវាសុខភាពផ្លូវចិត្តសាធារណៈ?

- ជនណាដែលមានវិបត្តិអាចទទួលសេវាផ្នែកវិបត្តិ ដោយមិនគិតពីលទ្ធភាពដើម្បីបង់ប្រាក់
- សេវាសំរាប់អ្នកជម្ងឺក្រៅនិងអ្នកជម្ងឺសំរាកក្នុងមន្ទីរពេទ្យ ដែលត្រូវការផ្នែកពេទ្យចាំបាច់ គឺអាចមានសំរាប់ពលរដ្ឋក្នុងយើងខោនធីដែល :
  - មានគុណសម្បត្តិសំរាប់ទទួលជំនួយមេឌីខេដ
  - មិនមានជំនួយមេឌីខេដ ប៉ុន្តែអ្នកដែលជួបនឹងលក្ខណៈវិនិច្ឆ័យនៃហិរញ្ញវត្ថុនិងការព្យាបាល

សេវានៃវិបត្តិនានា

បណ្តាញវិបត្តិ (24 ម៉ោង)
ការផ្តល់ឱវាទ, ព័ត៌មាន, ការទាក់ទង, ឬការបញ្ជូនទៅធនធាននានាផ្សេងទៀតភ្លាមៗ។

សំឡេង :	**206-461-3222**
លេខមិនគិតថ្លៃ :	**866-427-4747 (866-4CRISIS)**
ទូរស័ព្ទ TTY :	**206-461-3219**

ប្រជាជនដែលទទួលសេវាមកពីទីភ្នាក់ងារសុខភាពផ្លូវចិត្ត សហគមន៍ ដែលកំពុងត្រូវការសេវាវិបត្តិ គួរទាក់ទងទៅទីភ្នាក់ងារនេះ។

សេវាជម្ងឺវិកលចរិតសំរាប់អ្នកជម្ងឺសំរាកក្នុងមន្ទីរពេទ្យ

- ការចុះឈ្មោះ *នៅមន្ទីរពេទ្យដោយស្ម័គ្រចិត្ត* ត្រូវតែមានការអនុញ្ញាតជាមុន។ ដើម្បីស្នើទូរសេវាកំរតនេះ
  - អតិថិជនបច្ចុប្បន្នគួរទាក់ទងទៅទីភ្នាក់ងារសុខភាពផ្លូវចិត្ត សហគមន៍របស់ពួកគេ
  - គ្រប់បុគ្គលម្នាក់ៗដទៃទៀតគួរ :
    - ទាក់ទងគ្រូពេទ្យថែទាំបឋមរបស់ពួកគេ,
    - ចូរទូរស័ព្ទទៅបណ្តាញវិបត្តិ, ឬ
    - អញ្ជើញទៅសង្គ្រោះអាសន្ន។
- ការវាយតំលៃសំរាប់*ការសំរាកក្នុងមន្ទីរពេទ្យផ្នែកវិកលចរិតដោយមិនស្ម័គ្រចិត្ត* គឺត្រូវធ្វើឡើងដោយអ្នកមានវិជ្ជាជីវៈផ្នែកសុខភាពផ្លូវចិត្តដែលបានចាត់តាំង។ ចូរទូរស័ព្ទទៅបណ្តាញវិបត្តិ ដើម្បីស្នើសុំប្រភេទនៃការវាយតំលៃនេះ បើជនណាម្នាក់ជាអ្នកមានគ្រោះថ្នាក់ដល់ខ្លួនឯង ឬជនដទៃដោយសារតែជម្ងឺផ្លូវចិត្តនេះ។

សេវាសំរាប់អ្នកជម្ងឺក្រៅ

ចូរទាក់ទងទៅទីភ្នាក់ងារសុខភាពផ្លូវចិត្តសហគមន៍ដែលមានរាយឈ្មោះនៅក្នុងកូនសៀវភៅនេះ ដើម្បីស្នើការណាត់ជួប។ ទីភ្នាក់ងារនឹងដឹកនាំធ្វើការវាយតំលៃ ដើម្បីកំណត់ថា ភាពចាំបាច់ផ្នែកពេទ្យនិងលក្ខណៈវិនិច្ឆ័យហិរញ្ញវត្ថុត្រូវបានជួប។ បើសិនជាបានជួបមែន នោះសេវានឹងត្រូវអនុញ្ញាតដោយ RSN នៃយើងខោនធី។ បើមិនជួបវិញ នោះការបញ្ជូនទៅធនធានសហគមន៍ផ្សេងទៀតនឹងបញ្ជូនទៅតាមសេចក្តីត្រូវការ។

សេវាសំរាប់អ្នកជម្ងឺក្រៅដែលអាចមាន

- អន្តរាគមន៍សង្គមនៃការព្យាបាល
- សេវាផ្នែកវិបត្តិនិងលំនឹង
- សេវាឧបត្ថម្ភពេលថ្ងៃ
- ការសំរួលនៃការវាយតំលៃនិងការព្យាបាលដាច់ឡែកតែឯង
- ការព្យាបាលម្នាក់ៗ, គ្រួសារ, និងជាក្រុម
- ការកត់ត្រាការវាយតំលៃ
- ការព្យាបាលយ៉ាងល្អិតល្អន់សំរាប់អ្នកជម្ងឺក្រៅ
- ការចាត់ចែងថ្នាំពេទ្យ
- ការត្រួតពិនិត្យថ្នាំពេទ្យ
- មន្ទីរកន្លែងសុខភាពផ្លូវចិត្ត
- សេវាសុខភាពផ្លូវចិត្ត នៅពេលធ្វើការរៀបចំសំរាកក្នុងមន្ទីរពេទ្យ
- សេវាឧបត្ថម្ភក្នុងលក្ខណៈស្មើគ្នា
- ការវាយតំលៃផ្នែកចិត្តវិទ្យា
- ការធ្វើឲ្យល្អឡើងវិញនៃការគ្រប់គ្រងសំណុំរឿង
- ការមើលថែជំនួសពេលមិននៅ
- ការវាយតំលៃប្រជាជនពិសេស
- ការងារធ្វើដែលមានការឧបត្ថម្ភ
- សេវាសមស្របទៅតាមវប្បធម៌និងអាយុ
- សេវាសវនាការ និង/ឬការបកប្រែភាសា

សេវាដែលគ្មានការធានាគ្រប់គ្រង

- ការដឹកជញ្ជូនពេលមិនបន្ទាន់អាសន្ន, មិនមែនផ្នែកពេទ្យ
- សំបុត្រទិញថ្នាំដែលមិនមែនសំរាប់វិកលចរិត
- សេវាមកពីទីភ្នាក់ងារសុខភាពផ្លូវចិត្ត ដែលមិនមានចុះនៅក្នុងកូនសៀវភៅនេះ លើកលែងតែបានអនុញ្ញាតដោយ RSN យើងខោនធី

ការជ្រើសរើសអ្នកធ្វើការឬទីភ្នាក់ងារ សុខភាពផ្លូវចិត្ត

បុគ្គលម្នាក់ៗដែលបានយល់ព្រមសំរាប់សេវាសុខភាពផ្លូវចិត្ត គឺមានសិទ្ធិដើម្បី :

- ជ្រើសរើសអ្នកធ្វើការផ្នែកសុខភាពផ្លូវចិត្ត មកពីអ្នកធ្វើការដែលអាចមាននៅក្នុងទីភ្នាក់ងារសុខភាពផ្លូវចិត្តរបស់ពួកគេ, បើគ្មានអ្នកជ្រើសទេ គឺនឹងត្រូវចាត់តាំងអ្នកធ្វើការម្នាក់។
- ប្តូរអ្នកធ្វើការផ្នែកសុខភាពផ្លូវចិត្តរបស់ពួកគេ ឬទីភ្នាក់ងារសុខភាពផ្លូវចិត្តនៅក្នុងរវាង 90 ថ្ងៃដំបូង នៃការចាប់ផ្តើមប់រើ ឬមួយឆ្នាំនៅក្រោយពេលនោះសំរាប់មានមូលហេតុណាមួយ។

សេចក្តីសំរេចលើកទីពីរ

បុគ្គលម្នាក់ដែល :

- មានការណាត់ជួបផ្តល់សំណុំរឿង ប៉ុន្តែត្រូវបានគេប្រាប់ថាគ្មានលក្ខណសម្បត្តិដើម្បីទទួលសេវានានា, ឬ
- ជឿថា ពួកគេត្រូវការសេវាផ្សេងទៀត ហើយត្រូវគេបានផ្តល់ឲ្យ,

មានសិទ្ធិស្នើសុំទីភ្នាក់ងារ ឲ្យផ្តល់សេចក្តីសំរេចលើកទីពីរ ដោយគ្មានគិតថ្លៃ។ សេចក្តីបង្គាប់មុនពេលសំរេច

សេចក្តីបង្គាប់មុនពេលសំរេច

សេចក្តីបង្គាប់មុនពេលសំរេចនៃសុខភាពផ្លូវចិត្ត (MHAD) គឺជាឯកសារជាលាយលក្ខណ៍អក្សរ ដែលអធិប្បាយនូវសេចក្តីបង្គាប់នៃជនម្នាក់ និងការចូលចិត្តសំរាប់ការព្យាបាលនិងការថែទាំក្នុងអំឡុងពេលដែលពួកគេមានការ ពិបាកក្នុងទំនាក់ទំនងនិងការធ្វើសេចក្តីសំរេច។ គឺអាចជំរាបទៅជនដទៃអំពីការព្យាបាលអ្វីដែលជននោះចង់បាន ឬមិនចង់បាន ហើយនិងវាអាចបញ្ជាក់ជនណាម្នាក់ ដែលហៅថា (ទីភ្នាក់ងារ) ដែលអាចត្រូវគេទុកចិត្ត ដើម្បីធ្វើការសំរេច និងដើរតួជំនួសជននោះ។
ជនម្នាក់ៗមានសិទ្ធិប្រតិបត្តិ MHAD ហើយនឹងត្រូវគេផ្តល់ព័ត៌មានជូនពីរបៀបអនុវត្ត ដោយទីភ្នាក់សុខភាពផ្លូវចិត្ត របស់ពួកគេ។ MHAD របស់ជននោះអាចចុះឈ្មោះតាមបណ្តាញអ៊ីនធឺណិតនៅ :
http://www.doh.wa.gov/livingwill/registerdoculments.htm

ការភ្ជាប់ភ្នែករដែលទាក់ទងនឹងការមិនធ្វើតាម MHAD អាចដាក់បណ្តឹងទៅក្រសួងអតិថិជននៃ RSN យើងខោនធី, ផ្នែកទទួលបណ្តឹង និងស្នើបន្ទូរបណ្តឹងការភ្ជាប់ភ្នែក, ឬ ទូរស័ព្ទទៅនាយកដ្ឋានសុខភាពផ្លូវចិត្តរដ្ឋតាមលេខ 1-888-713-6010 ។

សេវាអតិថិជន

សេវាអតិថិជន, សេវា RSN នៃយើងខោនធី, ផ្តល់ទូវ :

- ព័ត៌មាននៃសិទ្ធិរបស់អតិថិជន។
- ការបញ្ជូនសំរាប់សេវាសុខភាពផ្លូវចិត្ត។
- ប្រយោជន៍សុខភាពផ្លូវចិត្ត, លក្ខណសម្បត្តិ, និងការទទួលព័ត៌មាននៃការមើលថែទាំ។
- ជម្រើសសំរាប់គាំទ្រការភ្ជាប់ភ្នែក, ភាពអយុត្តិធម៌, ការធ្វើឧទ្ធរណ៍, និងដំណើរការសវនាការយុត្តិធម៌។

ការទទួលបណ្តឹងនិងស្នើបការភ្ជាប់ភ្នែកផ្នែកសុខភាពផ្លូវចិត្ត

សេវាទទួលបណ្តឹង និងស្នើបការភ្ជាប់ភ្នែក :

- គឺសំរាប់បុគ្គលម្នាក់ៗដែលទទួលសេវាសុខភាពផ្លូវចិត្ត ដែលចេញប្រាក់ដោយជំនួយសាធារណៈ ដែលមានអារម្មណ៍ថា សិទ្ធិរបស់ពួកគេត្រូវបានគេបំពាន ឬពួកគេមិនបានទទួលការបំពីគ្រប់គ្រាន់។
- ជួយបុគ្គលម្នាក់ៗក្នុងការដោះស្រាយបញ្ហានានា, ការភ្ជាប់ភ្នែក, ភាពអយុត្តិធម៌, ការធ្វើឧទ្ធរណ៍, និងដំណើរការសវនាការយុត្តិធម៌។
- ធ្វើការដើម្បីទទួលដំណោះស្រាយដែលជួបតាមសេចក្តីត្រូវការរបស់បុគ្គលម្នាក់ៗ និងក្នុងកំរិតទាបបំផុតដែលអាចធ្វើទៅបាន។
- គឺទីភ្នាក់ងារបំពីការងាករវាងនៃ RSN យើងខោនធី។

សេវាគឺលាក់ការសម្ងាត់, មិនគិតថ្លៃ, និងការពារអ្នកទទួលជំនួយកុំឲ្យមានការសងសឹកនៅក្នុងប្រភេទណាមួយ។

សិទ្ធិឯកជន និងភាពលាក់ការ

- សិទ្ធិឯកជននៃបុគ្គលម្នាក់ៗក្នុងការទទួលសេវាសុខភាពផ្លូវចិត្តគឺត្រូវបានច្បាប់ការពារ។
- គ្រប់ព័ត៌មានទាំងអស់អំពីបញ្ហាសុខភាពផ្លូវចិត្ត និងការព្យាបាលរបស់បុគ្គលម្នាក់ៗគឺលាក់ជាសម្ងាត់ ហើយនឹងមិនចែកចាយទៅក្រៅទេ លើកលែងតែច្បាប់បានអនុញ្ញាតឲ្យ។

សេវាដែលមានការសមស្របតាមអាយុ, វប្បធម៌, ភាពពិការ, និងភាសាច្រើនសញ្ជាតិ

- សេវាដែលបានផ្តល់គឺសមរម្យត្រឹមត្រូវទៅតាមអាយុ, វប្បធម៌, និងភាពពិការរបស់បុគ្គលម្នាក់ៗ។
- អាចមានអ្នកបកប្រែភាសា ទៅតាមភាសាកំណើតរបស់បុគ្គលម្នាក់ ដោយមិនគិតថ្លៃឈ្នួលឡើយ។